# ការសំភាសន៍ជាលើកទី២របស់អ្នកមីង ណៃ ស៊ីណាត

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវសំភាសន៍ណៃ ស៊ីណាត

## ការសង្ខេបរបស់អ្នកមីង ណៃ ស៊ីណាត

អ្នកមីង ណៃ ស៊ីណាតគាត់ក៏បានកើតទាន់របបប៉ុល ពតផងដែរ គាត់ហូបក៏មិនសូវគ្រប់គ្រាន់ហើយគាត់បានឃើញសាកសពគេបានដាក់ចូលក្នុងពាង ហើយគាត់នៅព្រែកហូរពេលក្នុងជំនាន់ប៉ុល ពតហ្នឹង ហើយគាត់ក៏រស់នៅទីហ្នឹងសព្វថ្ងៃដែរ។ ជីវិតអ្នកមីងគឺមានភាពលំបាកខ្លាំងហើយគាត់រកស៊ីការងារសព្វគ្រប់ទាំងអស់ដើម្បីចិញ្ចឹមជីវិត ហើយ គាត់មានស្វាមីដែលស្លាប់បាត់ ហើយគាត់ឥឡូវមានស្វាមីមួយទៀតគឺដើម្បីជួយមើលថៃគ្នាពេលចាស់ទៅហើយគាត់មានបន្ទុកជាច្រើនត្រូវរ៉ាប់រងព្រោះកូនគាត់បានស្លាប់បាត់ហើយបានបន្សល់កូនតូចៗនៅហ្នឹងគាត់។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងជាលើកទី២នាងខ្ញុំឈ្មោះញ៉ែម សុគន្ធាជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍នៅក្នុងខែមិនា ឆ្នាំ២០១៨ការសំភាសន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រទេសកម្ពុជា អញ្ចឹងដោយពេលមុនត្រឹមតែរៀបរាប់ខ្លះៗអំពីជីវប្រវត្តិនៅក្នុងក្រុមគ្រួសារទាំងអស់ទេតែអ្នកមីងអត់ទាន់បានរៀបរាប់អ្វីទាំងអស់ហ្នឹងទេ!!អ៊ីចឹងអើរអ៊ីចឹងពួកយើងសួរសំនួរអ្នកមីងបន្ថែមទៀតទៅលើអ្វីដែលអ្នកមីងអត់ទាន់បានប្រាប់ពីពួកយើងទាំងអស់គ្នា អូខេ អញ្ចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញម្ដងទៀត!!

ខៈ ចាំ!!

កៈ ឈ្មោះអីគេវិញ?

ខៈ ញ៉ុមហោ?

ក៖ ចាំ!!

ខ៖  ណៃ ស៊ីណាត។

ក៖  ចាំអញ្ចឹងអ្នកកមីងឈ្មោះ ណៃ ស៊ីណាត
អ៊ីចឹងអ្នកមីងសំរាប់ការសិក្សាររបស់អ្នកមីងអ្នកមីងធ្លាប់ចូលសាលាអត់?

ខ៖  ញុំមធ្លាប់ចូលដែរតែវាអត់ទៅរៀន។

ក៖  ម៉េចអ៊ីចឹង?

ខ៖  វាអត់បានរៀនរវល់តែធ្វើការអីហ្នឹងហាំ!!

ក៖  ចាំតែអ្នកមីងធ្លាប់ចូលរៀនអត់?។

ខ៖  ធ្លាប់ចូលរៀនដែរ ធ្លាប់ទៅរៀន
មករៀនបានបន្តិចអាលែងជាប់ធ្វើការជាមួយម៉ែទៅលែងបានរៀន។

ក៖  រៀនបានថ្នាក់ទីប៉ុន្មានវិញអញ្ចឹង?

ខ៖  បានថ្នាក់ទី២អីវ៉ាន់ហ្នឹង!!

ក៖  ហ៊ីបានរៀនដែរតើ!! អ៊ីចឹងមីងរៀនបាន២ឆ្នាំហ្នឹងណោះបានថ្នាក់ទី២?

ខ៖  ចាំ!!

ក៖  អញ្ចឹងមីងពេលរៀនហ្នឹងហាំមីងរៀននៅសាលាបឋមសិក្សាណាដែរ?

ខ៖  ព្រែកហូរយើងហ្នឹង។

ក៖  ចាំហ្នឹងហើយគេដាក់សាលាបឋមសិក្សាហោង សំរិន ព្រែកហូរហ្នឹងមីងណោះ?

ខ៖  ចាំ!!

កៈ
អឺចឹងសាលាហ្នឹងកាលញុំមនៅពីក្មេងញុំមរៀននៅហ្នឹងដែរ!!តែអ្នកមីងសិស្សច្បងជំនាន់មុនរៀននៅហ្នឹង!!

ខៈ ចាំ!!

កៈ មីងពេលរៀនចេះច្រើនអត់?

ខៈ វាអត់ចាំដែលអូនចាំតិចៗ។

កៈ ចាំតែអ្នកមីងឥឡូវអ្នកមីងចេះសរសេរអក្សរអានភាសាខ្មែរបានច្បាស់អត់?

ខៈ អត់បានផង វាអត់ចាំ!!

កៈ ចាំ!!

ខៈ ចេះតែអត់ចាំ។

កៈ អឺអានអក្សរអីវ៉ាន់អត់រួចទេខ្មែរយើងហ្នឹងមីងណោះ?

ខៈ ចាំ!!អត់ចាំទេមីអូន។

កៈ អ្នកមីងដែលមានបំណងប្រាថ្នាអ្នកមីងពីក្មេងមកធ្វើអីគេអត់?

ខៈ ដឹងចង់ធ្វើអីគេទេនេះ?

កៈ និយាយថាពីក្មេងហាំ?

ខៈ ចាំ!!

កៈ អ្នកមីងគិតថាធំឡើងចង់ធ្វើអីគេដែរ ដែលចង់ធ្វើគ្រូបង្រៀនធ្វើអីអត់?

ខៈ អត់ចេះអត់ចង់ផង។

កៈ អត់ចេះ!!ពេលនៅពីក្មេងហ្នឹងធំឡើងហ្នឹងចង់ធ្វើអីគេវិញអញ្ចឹង?

ខៈ ដូចញុំមអាលែងកំពុងធ្វើសំរាមធ្វើអីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ធ្វើរាល់ថ្ងៃហ្នឹង ធ្វើសំរាមអោយគេ នៅផ្សារយើងហ្នឹងញុំមធ្វើសំរាមអោយគេរាល់ថ្ងៃហ្នឹង លើកដាក់លើរទេះ លើកដាក់សំរាមអោយគេអញ្ចឹងទៅ ដល់ខែគេអោយលុយទៅ ទិញអីហូបបាយទៅ។

ក៖ អាហ្នឹងសំរាប់បច្ចុប្បន្នហ្នឹងទេហោ?ខ៖ ចាំ!!ក៖ តែពីក្មេងមកអត់គិតដែលថាចង់ធ្វើអីមួយទេអញ្ចឹងហោ?

ខ៖ អត់ធ្វើរាល់ថ្ងៃធ្វើៗយូរមក។

ក៖ ដឹងហើយតាំងពីក្មេងមីងដឹកសំរាមហ្នឹងដែរហោ?

ខ៖ ចាំចាំ!!

ក៖ អញ្ចឹងសំរាប់នៅពីក្មេងអត់ដែលចង់មានក្តីប្រាថ្នាធ្វើអីទេអញ្ចឹង?

ខ៖ ចាំ!!

ក៖ អញ្ចឹងចេះតែរស់នៅរស់នៅធម្មតាអញ្ចឹងទៅមីងណោះ?

ខ៖ ចាំចាំៗ!!កាលពីមុនចេះតែបោកខោអាវទៅ បានមួយគែរមួយគែអញ្ចឹងទៅ រស់បានតែមួយគែរអញ្ចឹងទៅហ៊ីទៅបោកខោអាវទៅបានមកបានជីវភាពមកទិញអង្ករហូបហូបម្ហូបអញ្ចឹងបបរូអញ្ចឹងទៅ បើអត់យើងអត់ទៅរកយើងបានអីដាច់ពោះងាប់។

ក៖ ពិបាកណាស់មីងអញ្ចឹង!!

ខ៖ ចាំចាំ!!

ក៖ អញ្ចឹងអ្នកមីងសំរាប់ចូលដល់ជីវិតរបស់មីងហាំ!!

ខ៖ ចាំ!!

ក៖ មីងរៀបការជាមួយស្វាមីមីងគាត់ឈ្មោះជ័រមីងណោះ?

ខ៖ ហ្នឹងហើយគាត់ឈ្មោះជ័រ។

កៈ មីងត្រកូលរបស់ពូជ័រឈ្មោះអីគេដែរមីងមានចាំទេ?

ខៈ  អត់ស្គាល់ផង។

កៈ
ចាំមើលនៅក្នុងសំបុត្រកំណើតក្រែងលោមានឈ្មោះប្តី!!អ៊ីចឹងពួកយើងបានរកបន្ថែមទៀតអំពីសៀវភៅគ្រួសាររបស់អ្នកមីង!!អ៊ីចឹងប្តីអ្នកមីងឈ្មោះអោម ជ័រគាត់កើតនៅក្នុងថ្ងៃទី០២ ខែ ០៣ ឆ្នាំ១៩៥៣ ចំពូជ័រអាយុច្រើនហើយអញ្ចឹង!!!

ខៈ  ចាំ!!

កៈ អញ្ចឹងអ្នកមីងរាល់ថ្ងៃពូជ័រស្លាប់បាត់ហើយអ្នកមីងមែនទេ?

ខៈ  ស្លាប់បាត់ហើយ។

កៈ មូលហេតុបានពូជ័រស្លាប់ពេលហ្នឹងមីង?

ខៈ  គាត់ក្អកហូបស្រាច្រើនពេក។

កៈ  ហ្ហ៎សុទ្ធតែផ្លូវហ្នឹង!!ម៉េចដែរអូននិយាយមើលថាប៉ាស្លាប់ថី?

(កូន)៖ អើរគាត់ហូបស្រាច្រើនពេកហើយអត់ហូបបាយទេ
គាត់ធ្លាក់ខ្លួនឈឺហើយហូបបារីតែប៉ុណ្ណឹងទេ ហើយមានស្រីទៀត ស្រី២នាក់
ហើយស្រលាញ់ម៉ែញុំមតែមួយទេពេលហ្នឹងហ្ហ៎!!អស់ហើយ!!

កៈ អញ្ចឹងដោយសារគាត់ហូបស្រាទៅកាត់ក៏ស្លាប់ទៅណោះ?

(កូន)៖ចាំ!!

កៈ  អើយអ៊ីចឹងពិបាកណាស់អ៊ីចឹង!!អូខេអ៊ីចឹងប្តីអ្នកមីងគាត់កើតនៅទឹកថ្លា
ខណ្ឌដង្កោរាជធានីភ្នំពេញ!!អ៊ីចឹងមីង មីងរៀបការជាមួយពូជ័រនៅឆ្នាំណាមីងចាំអត់?

(កូន)៖ គាត់អត់ចាំទេអូនអើយ!!តាំងពីជំនាន់អ៊ុន តាក់ជំនាន់អីមក បងក៏អត់ចាំដែរ!!

កៈ  យូរហើយហោ?

ខ៖  នេះនេះរបស់គាត់ហេឈ្មោះគាត់(សំបុត្រកំណើតស្វាមីគាត់)នេះ!!

ក៖  អ៊ីចឹងនេះជាក្រដាស់ស្នាមអីពេលគាត់នៅរស់មឹងណោះ?

ខ៖   ចាំ!!

(កូន)៖ គាត់ធ្វើទាហានដល់ពេលគាត់ស្លាប់ទៅអត់មានបានអាកងពិបាកអី!!

ក៖  ហាំអ៊ីចឹងពូពិការដែរអ៊ីចឹង?

ខ៖   ចាំ!!ពិបាក។

(កូន)៖ ពិការតើអូន!!

ក៖  ពីការជើងហីអី?

(កូន)៖ ចង់និយាយថាគាត់ធ្វើទាហាន គាំតអើរ គាត់គ្រាប់ជាតិអំបែងនៅក្នុងខ្លួនហាំ!!
គ្រាប់កាំភ្លើងបៀមជាប់បេះដូង
ត្រឹមតែចប់មួយវគ្គដែលគាត់ថាគេចប់រឿងសង្គ្រាមអីមកអញ្ចឹងណាស់!

ក៖ ហ៊ឺៗ!!

ខ៖  គាត់នៅមានជំងឺហ្នឹងខ្ទប់ជាប់នៅក្នុងខ្លួន អ៊ីចឹងបានគាត់ស្គម។

ក៖  អ៊ីចឹងស្អីគេ អ៊ីចឹងមានគ្រាប់នៅជាប់បេះដូងនៅហ្នឹង?

(កូន)៖ បៀមជាប់បេះដូង។

ក៖  ហើយគេអត់វះកាត់ចេញទេអ៊ីចឹង?

(កូន)៖ បើសិនជាគេវះគាត់នឹងស្លាប់ វាចំពោះយើងវាអត់មានលុយ ខាងគេក៏គេជួយដែល
ក៏ប៉ុន្តែអាជីវភាពយើងអានេះវាអត់មានសំរាប់យើងទៅហូបចុក បបរ អាតិចតួច
តិចតួចហ្នឹងអូនណាស់!!

ក៖ ហ៊ឺៗ!!

(កូន)៖ហើយអ៊ីចឹងគាត់ទុកអញ្ចឹងហើយការអាមួយរយៈដែលគាត់ឈឺហ្នឹង
បើសិនជាគាត់អត់ហូបស្រា ធ្វើទុក្ខអាគាត់ក្តៅ
ធ្វើទុក្ខអោយគាត់ញាក់ដូចរបៀបអាគ្រុនចាញ់អញ្ចឹងណាស់!!

ក៖ ហ្អ៊!!

(កូន)៖តែអាជាតិអំបែង អាអំបែងខ្លាអីគេនោះ លឺតែគេនិយាយហ្នឹងហា៎!!ច្រើនកន្លែងណាស់
គាត់អត់មានវះអត់មានអីទេ!!ទុកទុក!!

ក៖ ហ្អ៊!!

(កូន)៖ហើយយូរៗវាទៅជាគ៉ាំរៃហា៎ជំងឺ!

ក៖ ហើយផឹកស្រាហ្នឹងដើម្បីទប់ទេ ដល់ពេលអញ្ចឹងវា!!

(កូន)ទប់វាដើម្បីកុំអោយឈឺចាប់អាជាតិរំសេវហ្នឹងវាធ្វើទុក្ខហា៎!!

ក៖ អញ្ចឹងស្រាហ្នឹងជួយបានពន្យាអាយុគាត់ទេ?

(កូន)៖ជួយដល់គាត់ ហ្នឹងហើយជួយរបៀបដូចគាត់អត់ឈឺចាប់!!

ក៖ ហ៊ីៗ!!អើយអញ្ចឹងពិបាកណាអ៊ីចឹងអានិតគាត់ណាស់មីង!!

(កូន)៖ ដល់ពេលគាត់ស្លាប់ទៅគាត់មានបានលក្ខណៈបានជា
ចុះខាងអ្នកណាគេធ្វើទាហានហ្នឹងគេមានអាអ្នកគេហៅថាស្មីគេបណ្ណ័កងពីបាកអីហ្នឹងហា៎!!សំរាប់ថាគាត់ស្លាប់ទៅអ៊ីចឹងគាត់មានប្រាក់ខែកូនអីអ៊ីចឹងហា៎!!តែគាត់អត់មានស្លាប់ទៅគឺគ្មានអីទាំងអស់!!

ក៖ ហ៊ីៗ!!

(កូន)៖អញ្ចឹងម៉ែគាត់!!

ក៖ ពិបាកអីអញ្ចឹងណាស់!!

(កូន)៖ចា៎!!

កៈ  មីងចាំទេថាពេលស្រលាញ់គ្នាជួបគ្នាដំបូងនៅពេលណា?

ខៈ   ញុំម៩៣(១៩៩៣)។

កៈ ៩៣(១៩៩៣)ហេ?

ខៈ  ចាំ!!

កៈ ជួបដំបូងពេលនៅឆ្នាំ១៩៩៣ហ្នឹង??

ខៈ   ចាំចាំ!!

កៈ
មីងការរៀបការរបស់មីងហាំរៀបចំឡើងដោយឪពុកម្តាយឬក៏មីងស្រលាញ់ពូដោយចិត្តឯង?
ហើក៏គេចូលស្តីដណ្តឹងមក?

ខៈ  ចូលដណ្តឹង!!

(កូន)៖ របៀបគេនិយាយទៅ គាត់ការហ្នឹងគាត់ការ
កាលពេលប៉ាបងនៅរស់គាត់និយាយប្រាប់បងដែរ។

កៈ  ម៉េចទៅ?

(កូន)៖ ថាគាត់តអ្នករត់ការខ្លួនគាត់
ឪពុកម្តាយខាងបងថាបងអញ្ចឹងថាអត់ពេញចិត្តម៉ែបងអញ្ចឹងហាំ!!តែឪពុកបងហ្នឹងគាត់រត់ការ
អោយដោយខ្លួនឯងអញ្ចឹង គាត់ស្មគ្រ័ចិត្ត។

កៈ  អញ្ចឹងឃើញអ្នកមីងក៏ស្រលាញ់អញ្ចឹងអ្នកមីងណោះ?

ខៈ   ចាំចាំ!!

កៈ ទោះម៉ែឪអត់យល់ព្រមម៉េចក៏នៅតែស្រលាញ់មីងដែរ?

ខៈ  ចាំ!!

កៈ អ៊ីចឹងរៀបការមកពូនជាចៅច្រើន!!

(កូន)៖ និយាយអោយចំទៅខាងឪពុកបងហ្នឹងគាត់អត់មានឪពុកម្ដាយទេ!!

ក៖ ហ្ន៎!!

ខ៖ គាត់មានតែម្ដាយចិញ្ចឹម។

ក៖ ម៉េចបានអញ្ចឹងដឹងទេបង?

(កូន)៖ ព្រោះគាត់ថាឪពុកគាត់ស្លាប់កាលពីសង្គ្រាម ដល់ពេលអីចឹងគាត់មានម្ដាយចិញ្ចឹមគាត់ណាស់!!គេស្រលាញ់គេអានិតគេចេះតែចិញ្ចឹមទៅ ដល់ពេលឥឡូវហ្នឹងប្អូនគាត់មួយនៅទឹកថ្លានោះ គេមានគេបាន តែដល់ពេលអត់ពីប៉ាបងទៅ បងនឹកឃើញថា យើងជាប់សាច់ឈាមមែនពិត តែដល់ពេលយើងអត់មានឪពុកយើងទៅ យើងទៅទីពឹងគេក៏មិនដឹងត្រូវថាថាម៉េច!!

ក៖ ហ្នឹងហើយ!!

(កូន)៖ យើងជាប់សាច់ជាប់ឈាមមែនពិតតែយើងជាមួយយើងយើងទៅសុំគេក៏ពិបាកដល់អីចឹងយើង ដល់ពេលលទ្ធភាពយើងខ្វះខាតតាមលទ្ធភាពអីចឹងទៅស៊ីបានព្រឹកខ្វះល្ងាចបានល្ងាចខ្វះព្រឹក តែជំបូលផ្ទះអូនឯងមើល មើលឃើញស្រាប់ហើយ!!បើពេលភ្លៀងវិញមិនបាច់ឈរទេអូន អូនឯងអង្គុយក៏អត់កើតដែរ!!

ក៖ ហ្នឹងហើយ!!

(កូន)៖ ស្រកទទឹកលិចពេញអស់ហើយ!!

ក៖ លិចមែនហ្នឹងហាំបានតែខែក្ដៅទេនេះ បានតែខែអត់ភ្លៀងទេ អញ្ចឹងពិបាករស់នៅណាស់!!មីងចាំទេថាខ្លួនឯងការហើយមានកូនជាមួយពូកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ញ៉ុមហោ?

ក៖ ចាំ!!

ខ៖  ញ៉ុមបាន!!

(កូន)៖ ចុះម៉ែឯងមិនរាប់ !!មីលាភ មីលា ញ៉ុមនេះហិ!! ៨នាក់នេះ!!អូន៥នាក់
៥នាក់តែស្លាប់ម្នាក់!!ស្លាប់៣ប្រុស!! ប្រុស២ស្រី៣!!

ក៖  ប្រុស២ស្រី៣អីចឹងហោ?

ខ៖   ហ្នឹងហើយ!!

ក៖  អញ្ចឹងនៅក្នុងសំបុត្រកំណើត អីចឹងប៉ុន្តែអត់ដាក់ឈ្មោះកូនស្លាប់ណាហី?

(កូន)៖ អត់ទេអូន!!

ខ៖   អត់ផង។

ក៖  អញ្ចឹងសំបុត្រកំណើតដាក់តែឈ្មោះកូនអោម វណ្ណា។

(កូន)៖ហ្នឹងញ៉ុម!!

ក៖  ហ្នឹងបងកើតនៅក្នុងឆ្នាំ១៩៨៥ ថ្ងៃ០១ខែ០២នៅសង្កាត់សុភមង្គល ទីរួមមខេត្តកណ្ដាល
ប្រទេសកម្ពុជាយើង!!ហើយកូនទី២ឈ្មោះអោម វាសនា!!

(កូន)៖ អាហ្នឹងប្រុស!!

ក៖  កើតថ្ងៃទី០៣ ខែ០៣ឆ្នាំ១៩៩២ប្រុស!! នៅភូមិព្រែកហូរ តាខ្មៅ ខេត្តកណ្ដាល
ស្រុកតាខ្មៅខេត្តកណ្ដាល កូនទី៣ឈ្មោះ អោម សុខលាភ ឥឡូវស្លាប់បាត់ហើយ!!

(កូន)៖ ឥឡូវស្លាប់បាត់ហើយ។ ស្លាប់បាត់នៅបន្សល់ទុកកូនតូច
កូនង៉ែតនេះនៅក្នុងអង្រឹងនេះមួយនឹងកូនដែលតូចៗ៣នាក់ទៀតទាំងអស់កូន៤នាក់ឥឡូវ!!

ក៖  មីលាភកូន៤នាក់?

(កូន)៖ ហើយធ្លាក់លើមីងចិញ្ចឹមទាំងអស់?

(កូន)៖ ធ្លាក់លើម៉ែទាំងអស់។

ក៖  ហើយចុះឪវា?

(កូន)៖ ឪវាមិនមែនថាវាអត់លុយប្រាក់ខែអីវាមិនមែនជាធំដុំអីទេ វាទៅធ្វើកម្មករអីគេដែរ
កាលណាវាទៅ ប្រាក់ខែគេអោយវាតែ៣០០០០០ទេ!!វាទៅធ្វើកន្លែងជ្រូកខ្ញែហ្នឹងហាំ!!
ដល់ពេលវាចេះវាមានបច្ចេកទេសវាដូចថាវាចេះជួយខ្ញែជួយអីគេអឺចឹងទៅ
គេអានិតវាគេអោយជាលុយរបបក្រៅ១០០០០ ២០០០០អីអឺចឹងទៅ
ហើយបើថ្ងៃណាវាទំនេរកន្លែងការងារវាទៅវាយកលុយមកអោយទិញទឹកដោះគោអោយកូន
បៅអញ្ចឹងទៅ!!

ក៖  ពិបាកណាស់អញ្ចឹងបងណោះ?

(កូន)៖ ហ្នឹងហើយ!!

ក៖ ចាំ!!អញ្ចឹងមួយទៀតឈ្មោះអោម ផល្លា កើតនៅក្នុងឆ្នាំ១៩៩៦
នៅថ្ងៃ០២ខែ០៩នៅភូមិព្រែកហូរស្រុកតាខ្មៅខេត្តកណ្ដាលដែរ!!អឺចឹងកូនចៅអ្នកមីងទាំងអស់
សុទ្ធតែមានប្ដីប្រពន្ធហើយអស់ហើយមីងហេ?

(កូន)៖ តែមី៧នេះក៏ពិបាកដែរបន្ទុកនៅលើម៉ែដែរ
មានប្ដីទី១បានត្រឹមតែរៀបដល់ពេលចាប់ផ្ដើមទំងន់គេរត់ចោលបាត់  រត់ចោលបាត់
ដល់ពេលកូនវានេះឥឡូវបានប៉ុណ្ណឹងហើយវាមានធ្វើការនៅលូ៥នោះធ្វើសន្តិចសុខហ្នឹងទៀត
វាទំងន់ទៀត
ទំងន់ទៀតតែគេអត់ទទួលការខុសត្រូវធ្វើជាឪពុកធ្វើជាអីអោយកើតកូនតែខ្លួនឯងទៀត
ជាមួយម៉ែហ្នឹងទៅទៀត!!

ក៖ អឺចឹងកូន២រាល់តែថ្ងៃហ្នឹង?

(កូន)៖ កូន២អូនតែអត់មានប្ដីនៅចិញ្ចឹមទេគឺគាត់អ្នកចិញ្ចឹមដែរ!!

ក៖ ហ្នំអញ្ចឹងបន្ទុកលើតែមីងទាំងអស់មីង?

(កូន)៖ លើមីងទាំងអស់!!

ខ៖   ហ្នឹងហើយបន្ទុកលើ។

កៈ ចាំ!!!ហើយចុះកូនដែលស្លាប់ហ្នឹងឈ្មោះអីគេវិញ?

(កូន)ៈឈ្មោះ អោម ចំរើន។

កៈ  ចាំតែអត់បានដាក់នៅក្នុងសៀវភៅគ្រួសារទេ!!

(កូន)ៈ អត់បានដាក់ក្នុងសៀវភៅគ្រួសារទេ!!

កៈ មូលហេតុអីបានកូនស្លាប់ដែរមីង?

ខៈ  វាពោះធំ!!!!

កៈ ពោះធំណាហី??

ខៈ   វាទាច!!

(កូន)ៈទល់អាចមន៍។

ខៈ   ទល់អាចមន៍ដូចវាទាចអញ្ចឹង!! វាទាចពោះហ្នឹងទាចធំម៉ង!!

(កូន)ៈ ជុះអាចមន៍អត់ចេះ។

ខៈ   ជុះអត់ចេញ។

កៈ  ហើយចុះមិនព្រមយកទៅពេទ្យ។

(កូន)ៈ យកទៅតើអូន!!

កៈ  តែវាស្ទះម៉ងហោ?

ខៈ  ចាំស្ទះ!!

(កូន)ៈ ហើយជុះអាចមន៍អត់ចេញហ្នឹងបានយកទៅពេទ្យគន្ធបុប្ផា ដល់ពេលយកមកវាបានធូរ បានជុះម្តងមួយយាមអ៊ិចឹងហើយដល់ពេលវាធ្លាក់លើកង់វាដាច់អាច្ទេរដែលដេរគេនោះ។

កៈ អានិតគ្នាណាស់!!

(កូន)៖ វាស្គម!!វាស៊ីអីអត់កើតវាស្លាប់អីចឹងម៉ងទៅ!!

ក៖ ចាំហ្នឹងហើយពិបាកណាស់អីចឹង!!មីងកូនទាំងអស់មីងបានអោយទៅរៀនខ្លះអត់?

ខ៖ វាបានរៀនដែរហ្នឹងហាំ!!

(កូន)៖ តែរៀនអត់ជាប់ៗ

ខ៖ តែរៀនអត់ជាប់ៗ

(កូន)៖ ថ្នាក់ទី១អីចឹងទៅម្នាក់ៗអត់ព្យាយាមរៀន រៀនដូចមីលាភ មីលាភរៀនបានទី២ បើអាប្រុសបានទី២ដែរ អាស្នាហាំ!!

ក៖ ហ៊ឺៗ!!

(កូន)៖តែរៀនអត់ចេះអក្សរទេបានតែថ្នាក់តែអត់ចេះអក្សរដូចរបៀបថាអត់មានចិត្តនៅក្នុងការចង់ចេះចង់ដឹងណាស់!!

ក៖ ហ្នឹងហើយ!!អាស្នាឥឡូវទៅណា?

(កូន)៖ ស្នានៅផ្ទះប្រពន្ធវានៅព្រៃកប្បស្សីហ្នំអូន!!តែញ៉ុមក៏អត់បានរៀនដែរ បានរៀនតែថ្នាក់ទាប ថ្នាក់ទី១ដែរ!!!

ក៖ ចាំ!!

(កូន)៖ តែគ្រាន់តែញ៉ុមអានដាច់សរសេរអត់កើត យើងគេដាក់អក្សរហ្នឹងយល់តើដល់ពេលអាន សរសេ សរសេរអត់ដាច់ សរសេរអត់ចេញ បានសរសេរខ្លះអត់ស្គាល់ស្រះដូចថាសរសេរអត់ចប់ហាំ!!

ក៖ ហើយឥឡូវ ឥឡូវបងអាយុប៉ុន្មានហើយ?

(កូន)៖ បងហេ!!បង៣២ហើយអូន!!

ក៖ ៣២ហេ?

(កូន)៖ ញ៉ុមកូន៤នាក់ឥឡូវហើយ!!

កៈ មីងចៅមិនមែនតិចទេនេះ !!សរុបចៅឥឡូវហ្នឹងប៉ុន្មានហើយ?

ខៈ ចៅច្រើនណាស់!!

(កូន)៖ ចៅជិត១០ហើយចៅ!!

កៈ ហើយកូនប៉ុន្មានសំបុកបន្ទុកលើមីងទាំង២ហើយ
(កូនស្រីទាំង២ចៅគឺបន្ទុកលើមីងទាំងអស់) ២សំបុកហើយនេះ!!

(កូន)៖២សំបុកហើយ!!

កៈ
អ៊ីចឹងមីងមីងអាចនិយាយប្រាប់ពីជីវិតមីងនៅពេលជំនាន់សង្គ្រាមប៉ុលពតហាំ!!!មីងកើតទាន់មែនទេ?

ខៈ ទាន់តើ!!

កៈ មីងអាចនិយាយប្រាប់មើលថាជីវិតមីងឆ្លងកាត់អីគេខ្លះនៅក្នុងជំនាន់ហ្នឹង
វាពិបាកម៉េចខ្លះ?

ខៈ ពិបាកហាពេលហ្នឹង ញ៉ុមទៅរើសអាចមន៍គោរើសអីហ្នឹង ជញ្ជូនអាចមន៍គោ
គេមិនអោយហូបបាយគ្រប់គ្រាន់អញ្ចឹងទៅ!!គេពិបាកអញ្ចឹងគេវ៉ៃជំធាក់អញ្ចឹងទៅ!!អ៊ីចឹងទៅ
យកអាចមន៍យកដាក់លើក្បាលអញ្ចឹងទៅ យកចេះតែទ្រាំទ្រាំទៅ
គេវ៉ៃផងអីផងរើសអាចមន៍គោដាក់អ៊ីចឹងទៅ។

កៈ ហ៊ី១ អ៊ីចឹងគេប្រើអីគេខ្លះមីង?

ខៈ ប្រើអញ្ចឹង!!

កៈ តែរើសអាចមន៍គោហ្នឹងហី?

ខៈ រើសអាចមន៍ហើយ
អាទឹកត្រីហ្នឹងយើងចង់លើត្រីហ្នឹងមកចងអ៊ីចឹងទៅទឹកត្រីយើងហ្នឹងអោយយើងផឹកមួយដប
មួយដបអ៊ីចឹងទៅ!!

ក៖  អាណាផឹកទឹកត្រីម៉េចមីងខាសកករងាប់ហើយ!!

(កូន)៖ លក្ខណៈថាយើងធ្វើខុស!!

ក៖ ហ្អ៎!!

ខ៖   យើងខុស!!

ក៖  ពេលមីងធ្វើខុសអីចឹងហោ?

ខ៖   ចាំ!!

ក៖  ហើយដល់ពេលអញ្ចឹងម៉េចទៅមីង ផឹកអស់ទេមួយដបហ្នឹង?

ខ៖   អត់!!អត់ផឹក!!

ក៖  ហើយអីចឹងបើសិនជាអត់ផឹកអីចឹង គេមិនស្តីអោយវ៉ៃងាប់ហើយ!!

ខ៖   គេវ៉ៃគេស្តីអោយអីអោយហើយហ្នឹង យើងយើងរត់ចេញទៅណាស់!!!!

ក៖ ចាំ!!

ខ៖   រត់ចេញទៅ។

ក៖  និយាយតែពួកអាពតហ្នឹងដូចរាងសាហាវដែរតើ!!ម៉េចរត់ចេញអីវ៉ាន់បាន?

(កូន)៖ ការចងចាំម៉ែបងអត់សូវចាំ!!

ក៖  អត់សូវចាំច្រើនមីងណោះ?

ខ៖   ហ្នឹងហើយ!!

(កូន)៖ ដូចថាសតិអារម្មណ៍គាត់ពេលហ្នឹងដូចគាត់មានការ ដូចថារបៀបថា កាលពេលបងចាំ ដោយសារតែយាយបងគាត់អ្នកប្រាប់ដែរទេណាស់!!

ក៖ ប្រាប់ពីប្រវត្តិរបស់មីងហោ?

(កូន)៖
ចាំហ្នឹងហើយ!!ម៉ែបងគាត់ក៏ភ្លេចភ្លាំងដែរ!!គាត់ថាកាលរយៈពេលក្នុងសង្គ្រាមហ្នឹងគឺគាត់គេហៅថា គេហៅថាអង្គការអង្គការគេហ្នឹងហ្នឹងហាំ កុមារគេហ្នឹងហាំ!!

ក៖ ហ៊ឺៗ!!

(កូន)៖
គេប្រើគាត់ទៅកើបអាចមន៍គោហើយដល់អ៊ីចឹងទៅហើយដល់គាត់ទៅកើបអាចមន៍គោក៏ដូចថារបៀបថាគាត់កើបហើយអីហើយអញ្ចឹង គាត់មានភ្លេចជាក្រមា កន្សែងអ៊ីចឹងហាំ គាត់ក៏ទៅយកអាកន្លែងហ្នឹងវាមានដើមពោធិ៍ហើយដើមពោធិ៍មានអ្នកតាមានអីអញ្ចឹងហាំ!!ដល់អញ្ចឹងគាត់ក៏ដើរទៅយកម្នាក់ឯងអ៊ីចឹងទៅ
ដល់អញ្ចឹងទៅអ្នកតាហ្នឹងក៏គេលងទាំងកណ្ដាលថ្ងៃត្រង់ម៉ោង១២នោះ!!

ក៖ អ៊ីចឹងទៀត!!

(កូន)៖ អាហ្នឹងយាយបងនិយាយប្រាប់បងទេណាស់!!

ក៖ ចាំ!ហ្នឹងហើយ!!

ខ៖  គាត់ថាអ្នកតាលងខ្មោច ថាស្អីៗអ៊ីចឹងទៅណាស់!! ហើយពីសង្គម
ហើយយើងជាក្មេងសម័យឥឡូវយើងអត់សូវដឹងច្បាស់តែចាស់និយាយប្រាប់រឿងពិតហើយបានគាត់និយាយ។

ក៖ ហ៊ឺៗ!

(កូន)៖ គាត់ថាអ្នកតាហ្នឹងទំលាក់អណ្ដាតទំលាក់អីដាក់គាត់អញ្ចឹង លង!!

ក៖  អាហ្នឹងដូចចង់ចូលខ្មោច!!

(កូន)៖ ចាំ!!ហ្នឹងហើយ ដល់ពេលអញ្ចឹងម៉ែបងគាត់បាត់ស្មារតីតាំងពីហ្នឹងមក
ការចងចាំថាដូចយើងនិយាយថាហេតុការអីដែលយើងចងចាំដឹងច្បាស់ៗដុចគាត់និយាយអត់ចាំអស់ហាំ!!

ក៖ ហ៊ឺៗ!!

ខ៖  អ៊ីចឹងគាត់ពិបាកតាំងពីហ្នឹងមករហូត!!ដល់ស្រុកយើងឥឡូវហ្នឹងសុខស្រួល។

ក៖
ហ្ន៎អ៊ីចឹងមីងអើរអត់សូវស្រួលក្នុងខ្លួនអត់សូវចងចាំច្រើនហ្នឹងដោយសារខ្មោចលងទេអញ្ចឹង?

ខ៖  ចាំ!!

(កូន)៖សតិអារម្មណ៍គាត់ហ្នឹងបាត់ដោយសារ
ដោយសារអំឡុងពេលដោយសារមានសង្គ្រាមហ្នឹង
ដល់ពេលចប់សង្គ្រាមហ្នឹងមករហូត!!ទល់តែឥឡូវហ្នឹងទៅណាស់!!

ក៖ ចាំ!!

(កូន)៖ ដូចថាការគាត់ដឹងទឹកលុយចំនួនដូចយើង សព្វដង
ដូចថាកាយសម្បទាយើងដឹងគ្រប់សព្វបែបយើងអាហ្នឹងយើងដឹងគេហៅអានេះប៉ុន្មានប៉ុន្មាន
ចំនែកគាត់ ញ៉ុមមិនមែននិយាយថាមើលងាយម៉ែទេណាស់!!

ក៖ ហ្នឹងហើយ!!

(កូន)៖ អានេះញ៉ុមដឹងតាមខ្សែរយៈម៉ាក់យាយញ៉ុម។

ក៖  ហ្នឹងហើយ!!

(កូន)៖ ព្រោះម៉ាក់យាយញ៉ុមជាម្តាយរបស់គាត់បង្កើតអ៊ីចឹងគឺគាត់ដឹងច្បាស់ហើយ!!
ដល់ពេលញ៉ុមឆ្ងល់
ដល់ពេលញ៉ុមក៏សួរម៉ាក់យាយញ៉ុមអញ្ចឹងអីអ៊ីចឹងនិយាយប្រាប់អីអញ្ចឹងទៅណាស់!!

ក៖ ហ៊ើៗ!!

ខ៖
ដល់អ៊ិចឹងគាត់ថាម្តាយញ៉ុមហ្នឹងកុំអីស្មារតីគាត់ហ្នឹងអត់អញ្ចឹងទេដោយសារតែមានហេតុការណ៍លងហេតុការណ៍បន្លាចគាត់ហ្នឹង។

ក៖ ហ្នឹងហើយហើយដោយសារខ្លាចពេកហ្នឹង!!

(កូន)៖ ហើយណាមួយហ្នឹងពេលវ៉ៃយហ្នឹងគឺគាត់នៅវ៉ៃយកុមារដែរផង ពេលដែលលងហ្នឹង មិនថាតែគាត់ទេ សូម្បីតែយើងសម័យឥឡូវនេះ!!

ក៖ ហ្នឹងហើយ!!

(កូន)៖ បើមានក៏យើងបាត់ការចងចាំដែរ!!

ក៖ មិនដឹងបាស់សក់ប៉ុណ្ណាទេ!!

(កូន)៖ កូន មិនស្រួលឈឺអត់មានថ្ងៃរស់ផង!!!

ក៖ ចាំ!!

(កូន)៖ ហើយគាត់ហ្នឹងដោយសារបានថ្នាំអំពេទ្យជូននេះម៉ាក់យាយបងថា !!ដល់ពេលមកស្រុកស្រណុកសុខស្រួលហ្នឹងគាត់មានប៉ាបងកំនើតបងហ្នឹងក៏គាត់នៅតែលំបាកទៀត ពិបាកម៉េច ពិបាកជីវភាពប៉ាបងគាត់ទៅរកឃ្មុំ ហើយម៉ែបងគាត់ពោះធំបងហ្នឹងគាត់ទៅច្រូតស្មៅ ទៅចុះស៊ីឈ្នួលគេទៅបាកំប្លោកហ្នឹងនៅអាកន្លែងវត្តយើងនេះ មុនមិនមានស្រះឈូក!!

ក៖ ចាំហ្នឹងហើយ!!

(កូន)៖ក្រោយកាវ៉ាស់សាំងហ្នឹងមិនមានកំប្លោកមានអី!!

ក៖ ហ៊ុៗ!!

(កូន)៖ដល់ពេលអីចឹងគេជួលគាត់គាត់ចុះទៅទាំងសរសៃខ្វីអីចឹងទៅណាស់!! អីចឹងគាត់ផ្នូនទុកជាន់ទុក ផ្នូនជាន់គ្នា ។

ក៖ ញ៉ុមតាំងពីកើតមកឃើញមីងមិនដែលស្រួលម៉េចទេ!!

(កូន)៖ចេញពីជំនាន់អាពតមកគាត់បាត់ស្មារតីអីចឹងហើយ ដល់ពេលស្រុកទេសស្រួលប្រួលហើយ គាត់អត់មានដើមទុនអីរកស៊ីអត់មាន ដីមានក៏ប៉ុន្តែមួយហឹកហ្នឹងបើគាត់ថាគាត់ចងចាំល្អដូចអស់គេ គេទិញគេលក់គេដូរគាត់ចេះទុកដាក់លុយកាក់ស្មារតីគាត់មាំហាំ!!ប្រហែលជាកូនជំនាន់ហ្នឹង

ប្រហែលជាអត់ពិបាកទេ!!ដោយសារតែគាត់ខ្វះក្នុងការសតិអារម្មណ៍គិតម៉ឹងម៉ាត់ដូចម្ដាយអូនឯងអ៊ិចឹងទៅណាស់!!

ក៖ ហ្នឹងហើយយល់!!

ខ៖
ហ្នឹងហើយដល់ពេលអញ្ចឹងធ្លាក់មកលើញុំមហើយនឹងគាត់សម័យអាពេលសុខស្រួលក៏នៅតែជួបអាជីវភាពពិបាកដដែល។

ក៖ ហ៊ុវទនាណាស់!!
បងបងឯងនិយាយពីជីវិតរបស់ម្ដាយរបស់បងឯងទាំងអស់មើលម៉េចដែរ?

(កូន)៖ គឺគាត់ពិបាកខ្លាំងណាស់មីអូន!!

ក៖ ដោយសារមីងគាត់អត់និយាយអត់សូវបានច្រើនទេ ដោយសារមីងគាត់ភ្លាំងភ្លាតច្រើន!

(កូន)៖ជីវភាពទី១គឺគាត់ខ្វះខាតក្នុងការអោយកូនៗដែលអត់មាននប្ដីហើយនឹងកូនដែលមានប្ដីអ៊ីចឹងប្រពន្ធស្លាប់អ៊ិចឹងទៅអ៊ីចឹងគឺគាត់ជាម្ដាយហ្នឹង
ទុកតែអត់ម៉េចក៏គាត់នៅតែរំលែកដែរគាត់រំលែកអោយស៊ីអោយចុកអ៊ិចឹងទៅណាស់!!។

ក៖ ចាំ!!

(កូន)៖ហើយគាត់មិនមែនជាអ្នកធ្វើការអីធំដុំអីទេគាត់អ្នកអនាម័យផ្សារអ៊ីចឹងដែរ។

ក៖ ហ្នឹងហើយ!!

(កូន)៖ អនាម័យផ្សារគេថាគេមើលឃើញគាត់គេអានិតគាត់ហើយ។

ក៖ ហ្នឹងហើយមួយៗគេអានិតគាត់ច្រើន
ដើរបោកខោអាវបោកអីអោយគេច្រើនអ៊ីចឹងទៅណាស់!!

(កូន)៖ ចាំ!!ពីមុនអត់ទាន់ចូលធ្វើអនាម័យគេហៅគាត់ទៅបោកខោអាវបោកអីអញ្ចឹងដល់ពេលគាត់ទៅផ្សារទៅអីអញ្ចឹងគេមើលឃើញគាត់ដូចថាមនុស្សគាត់ឧស្សាហ៍អ៊ិចឹងដែរហ្នឹងហាំ!!ហើយអ៊ិចឹងគេជ្រើសរើសគាំតជាអ្នកអនាម័យផ្សារអ៊ិចឹងទៅណាស់!!

ក៖ ហ៊ីៗ!!

ខ៖  អ៊ីចឹងប្រាក់ខែគាត់ក៏អត់បានច្រើនប៉ុន្មានដែរមួយខែឮថាបានតែ៩០០០០០ តែគាត់ធ្វើទាំងប្តីទាំងប្រពន្ធហា៎!!គាត់មានគ្រួសារក្រោយដែរ តែគ្រួសារក្រោយគាត់ចាស់!!

ក៖  ហ្ន៎អ៊ិចឹងមីងមានប្តីក្រោយទៀត?

(កូន)៖ ចា៎!!គ្រួសារគាត់ក្រោយចាស់!!

ក៖  ហើយឥឡូវប្តីក្រោយគាត់នៅណាវិញ?

(កូន)៖គាត់រត់ម៉ូតូឌុបរាល់ថ្ងៃអូន!!តែគាត់ក៏អត់ជាដែរ ហើយបងជាកូននឹកឃើញថាបងក៏មានលទ្ធភាពអីជួយដល់ម្តាយហើយកាលណាគាត់ឈឺឈឺ ចាប់គ្រុនរងាអី បងមើលបានខ្លះតែដល់ពេលចាស់ៗគ្នាគាត់គាត់ដឹងគ្នាគាត់ហា៎!!អ៊ីចឹងគាត់មើលគ្នាទៅមក ហើយរកមក តារត់ម៉ូតូឌុបរាល់ថ្ងៃបានត្រឹមតែម៉ាហូបម៉ាហូប ទិញម្ហូបមក១០០០០ ២០០០០អ៊ីចឹងទៅ!!អោយលៃព្រឹកល្ងាចមើលចៅ៥ ៦នៅលើគាត់ទាំងអស់ហ្នឹង!!

ក៖  ហើយប្តីក្រោយឈ្មោះអីគេមីង បង?

(កូន)៖ គាត់ឈ្មោះជឹម។

ក៖  តាជឹម?

(កូន)៖ ចា៎!!

ក៖ គាត់មកពីណាវិញញ៉ុមអត់ដែលឃើញ?

(កូន)៖ គាត់មកពី ស្អីគេលិចនេះ គេហៅស្អីគេញ៉ុមភ្លេចបាត់ទៀតហើយនេះ!!

ក៖  នៅព្រែកថ្លឹងព្រែកអីនេះ?

(កូន)៖ មិនមែនទេអូន នៅខាងតាកែវ។

ក៖  ហើយមីងមើលម៉េចបានជួបប្តីក្រោយមើលប្រាប់តិចមើលថីបានជួបប្តីក្រោយ។

ខ៖  ទឹមចំបក់ហ្នឹងគាត់ថាអត់មានគ្រួសារគេរស់នៅជាមួយយើង។

ក៖ ហ្ហ៎!!

ខ៖  ចេះតែ ចេះតែរកស៊ីជាមួយយើងទៅណាស់!!

ក៖  ហើយប៉ុន្មានឆ្នាំហើយដែលមានស្វាមីក្រោយហ្នឹង?

(កូន)៖ រយៈពេលដែលគាត់ជួបគ្នាហ្នឹងគាត់ដូចអត់ចងចាំ បងអ្នកចងចាំ!!

ក៖  ប៉ុន្មានឆ្នាំហើយ?

(កូន)៖ និយាយទៅ២ឆ្នាំហើយអូន។

ក៖ ហ្ហ៎ទឹមដែរហ្នឹងអ៊ីចឹង?

(កូន)៖ទឹមតែជួបគ្នាដែរ២ឆ្នាំ
២ឆ្នាំហ្នឹងពេលដែលបងទៅនៅកំពង់ចាមស្រុកខាងប្ដីទៀតបងអត់ដឹងហ៎!!

ក៖ អត់ដឹងរឿងហេ?

(កូន)៖
ហើយដល់ពេលគាត់ជួបគ្នាអញ្ចឹងទៅបងក៏នឹកឃើញថាហ៊ីបងក៏មានកូនមានចៅហើយនៅថែទាំកូនចៅបង គាត់កូនតូចៗចៅតូចៗអ៊ីចឹងអត់មានអ្នកណាមើលថែទាំគាត់បានទេ ចៅឈឺគាត់ ចៅអត់ស៊ីគាត់ ដល់ពេលប្អូនៗបងវារកមកសំរាប់តែប្ដីវាកូនវាដែរ ដល់ពេលគាត់ឈឺអ៊ីចឹងកូនៗអត់មានទឹកលុយដូចថាយកម្ដាយទៅពេទ្យ២០០០០០ ៣០០០០០ ៤០០០០០អ៊ិចឹងទៅណាស់!!

ក៖ ហ៊ឺៗ!!

(កូន)៖
អ៊ីចឹងបងនឹកឃើញថាគាត់ជួបគ្នាគូគ៉ាតដែរហើយព្រោះគ៉ាតបងគិតថាខ្លួនបងមិនមែនជាម៉ែគាត់ទេ បងគិតថាតែខ្លួនបងផ្ទាល់អ៊ិចឹងដូចប្ដីបងអញ្ចឹង គួរហើយបានបងជួបអ៊ីចឹងបងគិតថាបើគាត់ចាស់ហើយគាត់ស្រលាញ់គ្នាអោយគាត់ស្រលាញ់ទៅណាស់!!

គាត់ធ្វើអើរដូចបងគិតថាបងមានបង្គោលមានទំនប់ជួយជាកំលាំងចិត្តបងដែរអឺចឹងទៅណាស់!
!

កៈ ហ្នឹងហើយ ហ្នឹងហើយ មីងនៅតែម្នាក់ឯងក៏ពិបាកដែរមីងមែនទេ?

(កូន)ៈ ចាំ!! កាលណាគាត់ឈឺគឺគាត់ដេកដួលហើយ ដេកដួលបងក៏អត់
ប្អូនៗក៏អត់បានអ្នកណាគេ!!

កៈ ហ្នឹងហើយ!!

ខៈ បើគាត់មានតាគាត់ទៅ
តាគាត់បានលុយតិចតួចទៅអត់ឃ្លានមានស៊ីគាត់យកប្រពន្ធគាត់ទៅពេទ្យហើយ!!

កៈ ចាំ!!តែគាត់អត់មានកូនអត់មានប្រពន្ធទេហី!!

(កូន)ៈ មានប្រពន្ធអូនតែគាត់អើយ លែងប្រពន្ធគាត់មុនទៅណាស់ !!

កៈ ហ្អ៎!!

(កូន)ៈតែក៏កូនគេសុទ្ធតែអ្នកធូរធារ កូនគេអ្នកមានអ្នកមានហាំ!!

កៈ តែគេអត់ជំទាស់អោយមកយកមីងដែរមីងហេ?

ខៈ អត់ផង!!

កៈ អត់អីដែរមីងណេះ?

(កូន)ៈ ព្រោះអីតាហ្នឹងគាត់លែងមកដោយចិត្តគាត់ខ្លួនឯងហើយកូនៗគេមិនថាម៉េចទេ
កូនៗគេក៏មានស្មគ្រ័ចិត្តថា មិនមែនថាម៉េចទេ អត់មានស្មគ្រ័ចិត្តដូចថា
ប្រឆាំងនឹងឪពុកគេដែរ។

កៈ ហ៊ឺៗ!!

(កូន)ៈ ព្រោះអីគាត់អស់ចិត្តដោយរៀងខ្លួនហាំ!!

កៈ ហ្នឹងហើយ។

(កូន)៖អ៊ិចឹងគាត់ចុះចេញមកគាត់មកជួបម៉ែនេះក៏ចេះនឹងចិត្តដែរ!!

ក៖ ហើយជួបគ្នានៅណាវិញមីង?

ខ៖ ចា៎!!ជួបគ្នានៅព្រែកហូរយើង!!

ក៖ នៅព្រែកហូរទេអ៊ីចឹង?

ខ៖ ចា៎!!

(កូន)៖
គាត់អ្នកអនាម័យហើយគាត់រត់ម៉ូតូឌុបហ្នឹងអូនឃើញគាត់មានចិត្តអានិតម៉ែបងហ្នឹងហា៎!!អញ្ចឹងគាត់ជួបគ្នាអញ្ចឹងទៅ!!ចាស់ៗគាត់មិនមែនដូចជាក្មេងទេ គាត់ដូចវ័យ៦០ឥលូវហើយ!!

ក៖ តែគ្រាន់តែរៀបរ៉ៃអីដែរមីងហោ?

ខ៖ រៀបតើអូន!!

ក៖ អីយ៉ាស់មីងហិ!!មើលមីងនិយាយពីជំនាន់ប៉ុល ពតថែមទៀតមើល មើលចាំអីគេខ្លះ ដឹងថាអត់សូវចាំច្រើនហើយតែចាំនិយាយដែលកន្លែងដែលចំនុចៗដែលចាំៗហា៎??មានដែលឃើញគេយកមនុស្សទៅសម្លាប់ចោលអីវ៉ាន់អត់?

ខ៖ ហ៊ឺ ចាប់នៅព្រែកហូរយើងហ្នឹងនៅក្រោយវត្តហ្នឹងគេ គេវ៉ៃអ៊ីចឹងទៅ ក្មេងៗប៉ុននេះយើងយកបោកចោលទៅ អានៅកន្លែងអាទឹកអណ្តូងហ្នឹង អាទឹកអណ្តូងធំៗហ្នឹង!!

ក៖ ហ្វ៎!!

ខ៖ អាអណ្តូងក្រោយហ្នឹង ក្រោយវត្តហ្នឹង!!

ក៖ ក្រោយវត្តិហ្នឹងហី?

ខ៖ អា
អារណ្តៅធំហ្នឹង!!ហើយបងត្រីវិញមួយប៉ុនៗនេះ!!!គេកាប់ចិញ្ច្រាំយកមួយកំនាត់ប៉ុននេះស្លរហូប

សុទ្ធតែខ្លាញ់ទាំងអស់រងើម ហើយឈាមឡើងអណ្ដែតត្រា!!ឈាម ឈាមមនុស្សហ្នំ!! កះ គេយកវ៉ៃចោលហ្នឹងហី?

ខះ  គេយកវ៉ៃចោលហ្នឹង!!កន្លែងហ្នឹងវ៉ៃចោលហើយសុទ្ធ មានគេវ៉ៃចោលច្រើនណាស់!!

កះ  អញ្ចឹងមីងនៅជំនាន់ប៉ុល ពត មីងនៅព្រៃកហូរទេអញ្ចឹងហោ?

ខះ  នៅព្រៃកហូរ!!

កះ  គេអត់មានជំលៀសទៅណាទេហី?

ខះ  គេអត់មានជំលៀសទៅណាទេនៅចំព្រៃកហូរហ្នឹងម៉ង!!

កះ
ហើយនៅស្រុកភូមិយើងម៉េចខ្លះទៅមីងញ៉ុមចង់ដឹងដល់ហើយថាទឹកដីដែលយើងនៅហ្នឹងអីអីចឹងវាម៉េចខ្លះទៅ?

ខះ  ញ៉ុមញ៉ុមទៅមុនដំបូងញ៉ុមថាអញ្ចេក ញ៉ុមយកអាសំរាប់ផឹកផឹកទឹកអីចឹង ពាងហាំឈាមឡើងពេញពាងទាំងអស់ទាំង៣ពាង!!វាដាក់ចូលក្នុងពាងហ្នឹងហាំ!!

កះ  វ៉ៃសំលាប់មនុស្សដាក់ចូលក្នុងពាងទៀត?

ខះ  ហ្នឹងហើយកូនក្មេងហាំ!!ដាក់ឡើងឈាមអណ្ដែតត្រាម៉ង!!

(កូន)៖
គាត់ចង់បានន័យថាសម្លាប់ដាក់នៅក្នុងពាង!!ហើយពេលដែលគាត់ស្រេកទឹកគឺអត់មានទឹកហូបក្នុងថ្លង់ហ្នឹងគឺមានតែថ្លុកឈាម គាត់ចង់និយាយថាអញ្ចឹង!!

កះ  ហើយមីងចាំអីគេទៀតមីងនិយាយអោយអស់មើល?

ខះ  មានតែចាំពីរបីមុខហ្នឹង។

កះ  ២ ៣មុខហ្នឹងទេហោ?

ខះ  ចាំ!!

កៈ អញ្ចឹងពេលធ្វើការគ្រាន់តែរើសអាចមន៍គោតែប៉ុណ្ណឹងទេហី?

ខៈ ចាំ!!

កៈ ហើយម៉ែឪម៉េចដែរនៅក្នុងជំនាន់សង្គ្រាមហ្នឹងម៉េចដែរពេលហ្នឹង?

ខៈ
ម៉ែញ៉ុមគាត់ទៅគាត់ទូលបាយយកអោយគេនៅជំនាន់អាពតគាត់ទូលបាយយកទៅអោយអ្នកស៊ីហ្នឹង ទូលបាយអឺចឹងទៅរែកបាយអោយគេអ្នក
អ្នកអត់អីហូបហ្នឹងទៅជួយគេចេះអានោះអោយអានោះអោយតិចៗទៅតាមផ្លូវទៅ!!

(កូន)៖
និយាយទៅយាយបងធ្លាប់និយាយប្រាប់បងដែរពីប្រវត្តិហ្នឹងកាលពីសង្គ្រាមហ្នឹងដូចថាបុណ្យរបស់គាត់ហ្នឹងមានដែរខាងមេទ័ពគេ
គេហៅមេទ័ពមេទ័ពហ្នឹងហាំ!!គេអោយរើសគាត់គេរើសគាត់ជាគណៈកងអាម៉េចគេទេ
ថាអោយគាត់ហ្នឹងជាអ្នកចំអិនបាយដើរចែកគេអឺចឹងហាំ!!ដល់ពេលហើយលើកអាជីទំនប់លើកអីហ្នឹង លើកទំនប់ប្រឡាយហ្នឹង ចែកគេចែកឯងហូបអឺចឹងទៅបានបាយហ្នឹងហាំ
តែមិនមែនចែកលក្ខណៈថាចែកហ្នឹងម៉ោងនេះត្រូវចែកម៉ោងនោះត្រូវចែកទេ!!

កៈ ហ៊ីៗ!!

(កូន)៖ ពេលធ្វើការបានល្អគឺបានបាយហូបពេលដែលអត់ធ្វើការបានល្អអត់បានបាយហូប!!

កៈ ពិបាកណាស់អ៊ីចឹង!!

(កូន)៖ ពេលគេធ្វើមិនល្អគេយកទៅកសាងលើកទីមួយអត់អីទេ
លើកទី២រហូតដល់លើកទី៣គេសម្លាប់ចោល។

កៈ ហ្នឹងហើយ។

(កូន)៖ គេវ៉ៃនឹងដងចបអីអ៊ីចឹងទៅណាស់!!

កៈ ចាំ!! ហើយបងប្អូនម៉េចដែរមើងបាននៅមូលគ្នាទេ?

ខ៖  អត់មូលគ្នាផង!!

ក៖  គេបំបែកទៅតាមកងចល័តអីអញ្ចឹងទៅហី?

ខ៖  ហ្នឹងហើយ!!ហើយណាមហ្នឹងក៏គេសម្លាប់ចោល ។

(កូន)៖ ម៉ាបងប្អូនគាត់យាយបងថាមានស្លាប់ មានស្លាប់កូនគាត់ម្នាក់!!

ក៖ ចាំ!!

(កូន)៖ ស្លាប់ម្នាក់ឈ្មោះអំណម។

ក៖ ចាំ!!

(កូន)៖ អាហ្នឹងស្លាប់នៅក្នុងសង្គ្រាមហ្នឹងម៉ង!!

ក៖  មើលមីងមិញប្រាប់ថាមានបងប្អូនតែ៥នាក់ទេតែយាយប្រាប់ពិតប្រាកដហាំ ប៉ុន្មានទៅ?

(កូន)៖ និយាយទៅ អំណមមួយ អំណូ គាត់ហ្នឹង
មីងភណ្ឌ័ពូនាងតានេះផ្សេងទេតាជាមួយតាណៃផ្សេងទេណាស់!!!អំណម អំណូ ម៉ែ មីងភណ្ឌ័ ៥នាក់អូន ៥នាក់ត្រូវរបស់គាត់ហើយ។

ក៖  អីចឹង៥នាក់ត្រូវរបស់គាត់ហើយប៉ុន្តែឪពុកមិនមែនតែមួយទេ?

(កូន)៖ ឪពុកផ្សេង ជំនាន់ប៉ុល ពតតាបងឈ្មោះតាប៉ាន់។

ក៖  តាប៉ាន់ទេហេ?

(កូន)៖ ចាំ!!!!ដល់ពេលផុតពីសង្គ្រាម
តាបងតាណៃនេះក៏គាត់ស្គាល់ក្នុងវ័យប្រលូកអាក្នុងសង្គ្រាមគេចគ្រាប់ហ្នឹងដែរក៏ប៉ុន្តែដល់ពេលដូចថាតាបងស្លាប់ទៅយាយបងផុតពីសង្គ្រាមទៅគាត់មានគ្រួសារក្រោយតាបង!

ក៖  តាណៃអីចឹងទៅហេ?

(កូន)៖ ចាំ!!

ក៖  តែមិនមែនតាបង្កើតទេមែនទេគ្រាន់តែជាតាចុងទេណោះ?

(កូន)៖ ចាំ!!

ក៖  ហ្នឹងហើយ។

(កូន)៖ យាយតែមួយតាផ្សេងគ្នា ។

ក៖ ចាំ!!

(កូន)៖ តែគាត់រាប់គ្នាដូចជាបងប្អូនដូចថាសាច់តែមួយ ព្រោះថាម្ដាយតែមួយឪពុកដទៃអីចឹងហាំ!!តែរាប់គ្នារហូតទាល់តែឥឡូវអត់មានបញ្ហាអីអញ្ចឹងហាំ!!!

ក៖ ចាំ!!

(កូន)៖ ពូបងក៏គាត់ជួយគាត់មើលមកបងពេលបងឈឺក៏គាត់ជួយជាលុយជាកាក់អីអីចឹង!!

ក៖  ហ្នឹងហើយ!!

(កូន)៖ ២០០០០ ៣០០០០ អីតាមគាត់មើលឃើញតាមលទ្ធភាពបងអីចឹងទៅ!!ជូនលុយបងហូបអីហូបអីអីចឹងទៅ!!គាត់មិនមែនគិតថាល្អអញ្ចេះមួយអញ្ចុះពីរអាក្រក់ល្អសរខ្មៅអីបងប្អូនគិតតាមខ្សែអីអញ្ចេះអញ្ចេះអត់ទេ!!គាត់គិតថាអោយតែចេញពីម្ដាយជាបងរបស់គាត់ទាំងអស់ហ្នឹង។

ក៖  ហ្នឹងហើយ!!

(កូន)៖ គាត់អត់គិតកាត់សាច់ដាច់អីអត់ទេ!!

ក៖  វាត្រូវតែបងប្អូនបង្កើតហើយដោយសារម្ដាយតែមួយដែរ!!

(កូន)៖ ចាំ!!

ក៖  ហើយមីងម៉េចដែរជីវិតដូចបានធ្វើការធ្វើការអីគេខ្លះនៅក្នុងជីវិត?

ខ៖   ញុំមហោ?

កៈ  បែកពីប៉ុល ពតមកហាំ??

ខៈ   បែកពីប៉ុល ពតហេ !!ញ៉ុមចេះតែទៅច្រូតស្មៅ ច្រូតអីលក់ទៅ
ចេះតែដោះស្រាយលក់រហូតទៅ បានហូប។

កៈ  មើលបើតាមញ៉ុមដឹងមីងធ្លាប់អើរ
អើរអូសទឹកលក់ទៀតហី?ហើយមីងដាក់អនាម័យនៅផ្សារ!!

ខៈ  ចាំ!!

កៈ  ហើយច្រូតស្មៅទៀត!!

ខៈ  ហ្នឹងហើយ។

(កូន)៖ ដើរបោកខោអាវអោយគេ។

កៈ  ដើរបោកខោអាវអោយគេ ងាប់បណ្ដោយអស់រលីងហើយហ្នឹង!! ហើយអីគេទៀតទេ?

(កូន)៖ ដើរលាងចានការបុណ្យអោយគេ។

កៈ  ហ្នឹងហើយ ការបុណ្យអីក៏ឃើញមានលាងដែរ!!មីងធ្វើការអត់រើសតែម្ដងម៉ងហាំ!!

(កូន)៖ ចាំ!!

កៈ  អោយតែបានលុយជួយកូន!!

(កូន)៖អោយតែបានលុយជួយដល់អោយថៅមានស៊ីគឺគាត់សុខចិត្តគាត់ថាកាត់កេរ្តិ៍កាត់ខ្មាស់
ទោះគាត់មានគាត់ក្រអីគាត់អត់គិតថាខ្លួនមានទេ ព្រោះអីជីវភាពគាត់លំបាកអញ្ចឹង
អោយតែគេជួលអោយតែគេហៅគឺគាត់ទៅទាំងអស់គឺគាត់អត់រើសអើង។

កៈ  ហ្នឹងហើយ មីងអើយមីង!!

(កូន)៖ ទាំងខ្លួនគាត់កំពុងមានជំងឺ!!គាត់រាល់ថ្ងៃមានជំងឺទឹកនោមផ្អែមទៀត!!

កៈ  អាហ្នឹងបើសិនជាគេថាមុតអីវ៉ាន់អញ្ចឹងហាំ!!ពិបាកណាស់!!

(កូន)៖ ចាំ!!ថាបើសិនជាមុតគឺក្លាយហើយអត់មានលុយមើលពិបាកហើយ ។

ក៖ អ៊ីចឹងត្រូវតែស្រួលប្រួលបន្តិចត្រូវតែកុំលែងជាមួយកាំបិតអី។

(កូន)៖ចាំ!!បានឥឡូវបានគាត់មានតាក្រោយហ្នឹងគាត់
ពេលគាត់ឈឺអ៊ីចឹងគឺតាក្រោយតាគាត់សុខចិត្តទៅធ្វើទាំងឈឺដែរ!!គាត់ធ្លាប់ម៉ូតូប៉ះពីរដងហើយឪពុកបងក្រោយហ្នឹងហ្នំ!!

ក៖ ចាំ!!

(កូន)៖អ៊ីចឹងគាត់ទៅទាំងឈឺប៉ះភ្លាមៗហ្នឹងគាត់អត់បានទៅធ្វើម៉ែបងគាត់ទៅធ្វើទាំងឈឈឺដែរ ហើយបងចេញទៅលក់រាល់ថ្ងៃនេះ!!

ក៖  លក់អីគេវិញ?

(កូន)៖ លក់បន្លែលក់អីតិចតួចៗនៅមុខរោងចក្រហ្នឹងអូន!!

ក៖ ហ្នំ!!

(កូន)៖ សាច់អីហ្នឹងគេជួលអោយលក់អូនអញ្ចឹងទៅលក់អស់អោយគេអញ្ចឹងទៅគេអោយលុយ ២០០០០ ២០០០០អ៊ីចឹងទៅ!!

ក៖  អញ្ចឹងមិនមែនរកស៊ីខ្លួនឯងទេអញ្ចឹង?

(កូន)៖ អត់ទេអូនបងអត់មានដើម។

ក៖ ហ្នំ!!

(កូន)៖
ដល់ពេលអញ្ចឹងបងស៊ីឈ្នួលគេដែរហ្នឹង!!ពីមុនបងដើរបោកខោអាវបោកអីអោយគេដែរហ្នឹង!!

ក៖ ហ៊ឺៗ!!

\(កូន)៖
កាលនៅក្រមុំបងនៅជាមួយអ៊ំបងនៅភ្នំពេញដល់ពេលបងចាប់ផ្តើមមានគ្រួសារចាប់ទៅច្រូត

ស្មៅច្រូតអីអញ្ចឹងទៅដូចម៉ែបងអញ្ចឹង របៀបដូចពាក្យថាដំណែល ដំណែលមិនមែនចង់បានទេ តែយើងវាអត់មានលទ្ធភាព!!

កៈ ចាំវាអត់ផ្លូវ!!

(កូន)ៈ ចាំអ៊ិចឹងវាសំខាន់កុំអោយតែយើងដើរខុសច្បាប់!!

កៈ ហ្នឹងហើយ!!

(កូន)ៈ អញ្ចឹងបងគិតថាអញ្ចឹងបងត្រូវតែតស៊ូទៅ!!បេះត្រកួន រ៉ាវខ្យង រ៉ាវក្តាម ឥឡូវហ្នឹងក៏នៅតែបេះត្រកួនដែរ!!

កៈ ឥឡូវមានត្រកួនណាបេះ?

(កូន)ៈ យើងជាអ្នកអត់មែនតែយើងត្រូវតែហុចលុយហ្នឹងទៅអោយគេមើលថាបងញ៉ុមលក់បានប៉ុណ្ណេះៗហើយហុចអោយគេ គេថាអត់យកទេ!!យកទៅដោះស្រាយទៅ។

កៈ យកទៅដោះស្រាយខ្លួនឯងអ៊ីចឹងទៅ?

(កូន)ៈ ចាំ!!!អ៊ីចឹងញ៉ុមលើកដៃសំពះគេអរគុណគេ។

កៈ ហ្នឹងហើយគេជួយយើងអោយមានអីរក!!អូខេអ៊ីចឹងមីងសង្ឃឹមអីគេទៅថ្ងៃក្រោយដែរនៅក្នុងជីវិតនេះហ៎?មានក្តីសង្ឃឹមអីទេ?

ខៈ អត់មានសង្ឃឹមអីទេរាល់ថ្ងៃ។

កៈ រាលថ្ងៃចេះតែរស់នៅធម្មតាអីអញ្ចឹងទៅ?

ខៈ ចាំ!!

(កូន)ៈ ព្រោះកូនអត់មានជីវភាពអីធូរធារផង!!!គាត់សង្ឃឹមថាបើសិនជាអត់ពីគាត់ទៅថាអោយតែមានផ្ទះដំបូលជិតដូចគេដូចឯង !!

កៈ ហ៊ឺៗ!!

(កូន)ៈ អញ្ចឹងគាត់អស់ចិត្តហាំ!!

កៈ ហ្នឹងហើយ។

ខៈ  វារហែកហេុយអិចឹងវាពិបាក!!

កៈ  អ៊ីចឹងបើលុយបើកអីមកទិញសង្ក័សីអីដាក់ទៅ!!

ខៈ   ចាំ!!

(កូន)ៈបើអាលែងយកលុយហ្នឹងទៅទិញ!!

កៈ អត់អីហ្វប!!

(កូន)ៈប្រចាំការរាល់ថ្ងៃ
ពេលខ្លះអ់តមានលុយហ្នឹងគាត់ខ្ចីពីប្រាក់ខែដែលជាប្រចាំរបស់គាត់ដែលធ្វើហ្នឹងយកមកប
ណ្តោះអោយចៅស៊ីរាល់ថ្ងៃនឹងដែរទៀត!!

កៈ  ហើយមីងអ្នកណាគេអ្នកបើកប្រាក់ខែអោយរាល់ខែ?ខាងផ្សារឬក៏ម៉េច?

ខៈ   តាម៉េត។

កៈ
តាម៉េតហេ!!ហ្ហំ!!អ៊ីចឹងមីងឥឡូវមួយនេះគឺជាសំនួរមួយចុងក្រោយអ្នកមីងមានពាក្យពេចន៍អីផ្តែ
ផ្តាំកូនចៅជំនាន់ក្រោយដែរ ចង់អោយគាត់ដើរលើផ្លូវអីគេដែរអ៊ីចឹងហាំ??

ខៈ   អើរអោយវាចេះអោយដើរផ្លូវអោយវាត្រូវៗទៅ!!ដើរលើផ្លូវអោយល្អទៅ!!កុំអោយខុស!!

(កូន)ៈ ខំប្រឹងរៀន!!

ខៈ   អោយខំរៀន!!

(កូន)ៈ កុំអោយល្វិតល្វង់ដូចក្រុមគ្រួសារ។

ក៖  អោយមួយៗក្រោយៗនេះហិ!!សុទ្ធតែប្រុស ប្រុសទាំងអស់មានស្រីខ្លះទេ?

ខ៖  មានតែនោះស្រីមួយមានពីរមានពីរ!!

ក៖  ស្រីមែន?

ខ៖  ហ្នឹងហើយស្រី ។

ក៖  អូយស្មានតែប្រុសលោកអើយលោក ស្មានតែប្រុស។

(កូន)៖ ហ្នឹងកូនលាភ។

ក៖  ហ្នឹងហើយ!!

(កូន)៖មានមួយហ្នឹងស្រី ហើយមីងឡាមានស្រីមួយដែរ។

ក៖  អ៊ីចឹងស្រីដែរហោ?

ខ៖  ស្រី!!

ក៖
អញ្ចឹងចៅច្រើនណាស់មីងហោ?មីងអត់សួរចាំប្រវត្តិច្រើនទេតែកូនបានជួយបំពេញ។អ៊ីចឹងអត់មានអីគេទៀតទេមីងណេះ?

ខ៖  ចា៎!!

ក៖ តែប៉ុណ្ណឹងទេមីងណោះ?

ខ៖  ចា៎!!

ក៖ អញ្ចឹងអរគុណមីង។